# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Aug-2014, 15:48
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តី មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖ **ប្តូរទៅជាសាធារណៈ**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើរបស់ មាស មុត សុំឲ្យផ្តល់ឯកសារទាំងអស់ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញានៅក្នុងខែ កក្កដា ឆ្នាំ ២០១៤

---

**ដាក់ដោយ:**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន:**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) តាមរយៈនេះ ស្នើសុំឱ្យផ្ដល់ឯកសារទាំងអស់ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញានៅក្នុងរឿងក្ដី ០០៣ ក្នុងខែកក្កដា ឆ្នាំ ២០១៤។ សំណើសុំនេះត្រូវបានធ្វើឡើងជាចាំបាច់ដោយហេតុថា របាយការណ៍តុលាការចុះខែសីហា ឆ្នាំ ២០១៤ ថ្លែងថា “ក្នុងអំឡុងខែ កក្កដា សហព្រះរាជអាជ្ញា ... បានដាក់ឯកសារចំនួនបីច្បាប់នៅក្នុងរឿងក្ដី ០០៣”[1] ក៏ប៉ុន្តែ មេធាវីការពារក្ដីបានទទួលឯកសារ *តែមួយច្បាប់គត់* ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងខែ កក្កដា[2]។ មេធាវីការពារក្ដីពុំទទួលបានឱកាសដើម្បីពិនិត្យមើលឡើងវិញ និង ឆ្លើយតបទៅនឹងឯកសារចំនួនពីរច្បាប់ផ្សេងទៀតនោះទេ។ ប្រសិនបើឯកសារដែលបានដាក់ដោយ ក.ស.ព. ត្រូវបានសម្រេចដោយពុំបានពិចារណាជាមុនលើការយល់ឃើញរបស់មេធាវីការពារក្ដីទេនោះ ករណីនេះនឹងរំលោភសិទ្ធិរបស់លោក មាស មុត ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ[3] ស្ដីពីការប្ដឹងតវ៉ា និង ការទទួលស្ដាប់កង្វល់របស់ខ្លួន[4]។ សិទ្ធិធ្វើការឆ្លើយតបគឺសំខាន់ណាស់ក្នុងការធ្វើកំណត់ត្រា និង យោងកំហុសភ័ន្តច្រឡំទាំងឡាយនៅពេលប្ដឹងឧទ្ធរណ៍។ សិទ្ធិនេះកើតចេញពីសិទ្ធិស្ដីពីគោលការណ៍ចំពោះមុខ រួម

---

[1] របាយការណ៍តុលាការ ចុះខែសីហា ឆ្នាំ ២០១៤ លេខ ៧៦ ទំព័រ ៥ អាចមើលតាមតាមរយៈគេហទំព័រ http://www.eccc.gov.kh/sites/default/files/publications/Court%20Report%20August%202014.pdf.

[2] ចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ និង សុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១៤ [សំណៅកោសលុបដាក់នៅថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៤] ឯកសារ D82/3/3/1.1។

[3] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវថា៖ “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ”។

[4] *សូមមើល* សៀវភៅប្រមូលផ្ដុំសេចក្ដីសង្ខេបនៃសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌អន្តរជាតិ (Legal Digest of International Fair Trial Rights) OSCE ឆ្នាំ ២០១៣ កថាខណ្ឌ ៦.៥.១៖ “គោលការណ៍នៃសវនាការប្រកបដោយភាពយុត្តិធម៌រួមបញ្ចូលអ្វីដែលប្រព័ន្ធយុត្តិធម៌ខ្លះហៅថាវិធានយុត្តិធម៌ធម្មជាតិ រួមទាំងទស្សនទាននៃ *audi alteram Partem* (ដែលមានន័យថា “ស្ដាប់ភាគីម្ខាងទៀត”)។ គោលការណ៍នេះត្រូវបានរកឃើញថាត្រូវបានរំលោភបំពាននៅក្នុងរឿងក្ដី *Hermoza តទល់នឹង ប្រទេសប៉េរូ* ដែលអាជ្ញាធររដ្ឋបាលបានដកហូតសិទ្ធិបង្ហាញការយល់ឃើញរបស់អ្នកដាក់ពាក្យសុំ ហើយអាជ្ញាធរដដែលនេះបានធ្វើសេចក្ដីសម្រេចព្យួរការងារ និង ក្រោយមកបញ្ឈប់គាត់ពីការងារ។ ភាពចាំបាច់ត្រូវស្ដាប់ភាគីម្ខាងទៀត មិនថានៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី គឺមានសារៈសំខាន់ និង ជាស្នូលនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌នៅក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងមាត្រា ៦(១) នៃអនុសញ្ញាស្ដីពីសិទ្ធិមនុស្សអឺរ៉ុប”។

ទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយផងដែរ[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពីមុនធ្លាប់បានទទួលស្គាល់រួចហើយថា គោលការណ៍សមភាពនៃមធ្យោបាយរវាងគូភាគីតម្រូវឱ្យផ្តល់ឱ្យមេធាវីការពារក្តីនូវឯកសារមួយក្នុងចំណោមឯកសារនានា ដែលបានដាក់នៅក្នុងខែ កក្កដា ដោយសហព្រះរាជអាជ្ញាអន្តរជាតិ[6]។ សិទ្ធិរបស់លោក មាស មុត ត្រូវតែបានគោរពដូចគ្នាទាក់ទងនឹងឯកសារពីរច្បាប់ផ្សេងទៀត។ ឯកសារទាំងឡាយដែលបានដាក់ដោយភាគីមិនដូចគ្នានឹងសម្ភារៈឯកសារនៅក្នុងសំណុំរឿង ដែលជាលទ្ធផលនៃការស៊ើបអង្កេត *ប្រកបដោយភាពអញ្ញាក្រឹត* ដោយសហចៅក្រមស៊ើបអង្កេតនោះទេ។ ភាគីត្រូវមានឱកាសឆ្លើយតបទៅនឹងឯកសារទាំងឡាយ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា និង ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្រែងលោសហចៅក្រមស៊ើបអង្កេតទទួលឥទ្ធិពលហួសហេតុពីឯកសារទាំងនេះ ដោយពុំបានពិនិត្យមើលជំហររបស់មេធាវីការពារក្តី។

អាស្រ័យហេតុនេះ យោងតាមហេតុផលទាំងអស់ដូចបានជម្រាបជូននៅក្នុងសំណើនេះ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតមេត្តា៖

---

[5] អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ០០១ បានបញ្ជាក់ថា "លក្ខណៈមូលដ្ឋាននៃ គោលការណ៍ [សមភាពនៃមធ្យោបាយរវាងគូភាគី] ត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង...។" *រឿងក្តី កាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D288/6.90 កថាខណ្ឌ ៤។ គោលការណ៍នេះគឺជាគោលការណ៍មូលដ្ឋាននៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា រួមទាំង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ ដែលអនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា អ.វ.ត.ក. ត្រូវគោរពតាម។ អនុលោមតាមមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ៖ "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និង មិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួនដោយសមធម៌ និង ជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមក លើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬ លើសិទ្ធិ និង ករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី..."។

[6] *សូមមើល* ការជូនដំណឹងលើកទីពីរពាក់ព័ន្ធនឹងលទ្ធភាពនៃការពិចារណាសារជាថ្មីលើសេចក្តីសម្រេចចំនួនពីរ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D82/3/3/3 ទំព័រ ៣។

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ក. **ផ្ដល់ឱ្យ**មេធាវីការពារក្ដីនូវរាល់ឯកសារទាំងអស់ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញានៅក្នុងខែ កក្កដា ឆ្នាំ ២០១៤ និង

ខ. **អនុញ្ញាតឱ្យ**មេធាវីការពារក្ដីមានពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងឯកសារទាំងនេះ ប្រសិនបើមេធាវីការពារក្ដីយល់ឃើញថាចាំបាច់ត្រូវឆ្លើយតប។

សូមលោកសហចៅក្រមស៊ើបអង្កេតទទួលយកសំណើនេះដោយក្ដីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២១** ខែ**សីហា** ឆ្នាំ **២០១៤**

សហមេធាវីការពារក្ដី លោក មាស មុត

អាង ឧត្ដម

Michael G. KARNAVAS